# មជ្ឈមណ្ឌលឯកសារកម្ពុជា

## របាយការណ៍
## ស្តីពីដំណើរចុះស្រាវជ្រាវនៅស្រុកកំពង់លែង និង ស្រុកជលគីរី
## ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១២-១៥ ខែមិថុនា ឆ្នាំ២០០០

---

ដោយ ផេង ពង្សរ៉ាស៊ី

ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ជាថ្ងៃដែលក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះទៅធ្វើការនៅខេត្តកំពង់ឆ្នាំង ជាពិសេសស្រុកកំពង់លែង និង ស្រុកជលគីរី ។ ក្រុមស្រាវជ្រាវយើងរួមមាន ស៊ិន យិន, អ៊ួច សំអឿន, ឃួយ វិសាលមុនី និង ផេង ពង្សរ៉ាស៊ី ។ តាមរបាយរណ៍ឆ្នាំ១៩៩៧ ស្រុកកំពង់លែង និង ស្រុកជលគីរី នៅមានទីតាំងមួយចំនួនដែលក្រុមស្រាវជ្រាវយើងមិនទាន់បានចុះដល់នៅឡើយ ព្រោះកាលនោះ (១៩៩៧) នៅមានពួកខ្មែរក្រហមឆ្លងកាត់ ដូចជាឃុំដារ និងឃុំប្រណូក ស្រុកកំពង់លែងជាដើម ។

ទើបតែនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជូនក្រុមស្រាវជ្រាវរបស់ខ្លួនចំនួនបួនរូប ដូចបានរៀបរាប់ឈ្មោះខាងលើ ចុះទៅធ្វើការសិក្សារស្រាវជ្រាវបន្តទៅលើទីតាំងដែលយើងពុំទាន់បានចុះកាលពីលើកមុន ។

ក្រោយពីបានធ្វើដំណើរតាមរថយន្តមួយគ្រឿងអស់រយៈពេលជិតពីរម៉ោងមក យើងក៏បានទៅដល់ទីរួមខេត្តកំពង់ឆ្នាំងនៅម៉ោង៩ៈ០៥នាទី ។ បន្ទាប់ពីធ្វើការទំនាក់ទំនងជាមួយសាលាខេត្តមក យើងបានធ្វើដំណើរបន្តទៅកាន់ស្រុកកំពង់លែងតាមទូកមួយគ្រឿង ដើម្បីស្វែងរកជួបអ្នកដែលបានដឹងឮ ព្រមទាំងចង់ទៅពិនិត្យផ្ទាល់ដល់ទីតាំង ។

នៅថ្ងៃដដែលនោះ (១២ ខែមិថុនា ឆ្នាំ២០០០) យើងបានធ្វើដំណើរទៅជួបលោកប្រធានឃុំដារឈ្មោះ ជឹម ចុន ។ លោកពូមានអាយុ៥៤ឆ្នាំ និង មានស្រុកកំណើតនៅភូមិ-ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ កាលពីជំនាន់លន់ ណុល លោកពូ ជឹម ចុន ធ្លាប់ធ្វើទាហាននៅទីរួមខេត្តកំពង់ឆ្នាំងចំនួន៥ខែ ។ ក្រោយមកគាត់ក៏បានវិលមកស្រុកកំណើតវិញបន្ទាប់ពីឪពុក-ម្តាយទៅទទួល ។ បន្ទាប់មក ជឹម ចុន ក៏ត្រូវរត់គេចខ្លួនបន្តទៅកាន់ឃុំចើងដើង ខេត្តកំពង់ធំទៀតដើម្បីគេចខ្លួនពីការតាមសម្លាប់នៃពួកខ្មែរក្រហម ។ លុះបានដំណឹងថានៅស្រុកកំពង់លែង លែងមានការសម្លាប់មនុស្សនាចុងឆ្នាំ១៩៧៤ ជឹម ចុន ក៏ត្រលប់មកស្រុកវិញ ។ ពេល

មកដល់ផ្ទះ លោកពូមិនត្រូវបានទទួលស្គាល់ពីញាតិមិត្ត-គ្រួសារឡើយ ហើយបន្ទាប់មកក៏ត្រូវចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរសន្តិសុខវៀងជួរចាស់ដើម្បីអប់រំសតិអារម្មណ៍ ។

១-<u>ឃុំដារ</u>

<u>មន្ទីរសន្តិសុខវៀងជួរចាស់ ឬ មន្ទីរសន្តិសុខភូមិចាស់</u>

មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិចាស់ ឃុំដា ស្រុកកំពង់លែង ។ តាំងពីសម័យប៉ុលពតរហូតមកដល់បច្ចុប្បន្ន មន្ទីរនេះមានឈ្មោះហៅខុសៗគ្នាដូចជា មន្ទីរចាស់, មន្ទីរភូមិចាស់, មន្ទីរភូមិគុយ និង មន្ទីរវៀងជួរចាស់ ។ ជឹម ចុន ជាអ្នកទោសមួយរូបក្នុងចំនោមអ្នកទោសរាប់រយនាក់នៅទីនោះ ។

យោងតាមសំដីរបស់លោកពូ ជឹម ចុន ថាមន្ទីរសន្តិសុខនេះត្រូវបានបែងចែកអ្នកទោសជាពីរផ្នែកគឺៈ មួយផ្នែកសំរាប់ដាក់អ្នកទោសជាប្រជាជនថ្មី (១៧មេសា) និង មួយផ្នែកទៀតសំរាប់ដាក់អ្នកមានគុណវិបត្តិ ។ **មន្ទីរគុណវិបត្តិ**ជាមន្ទីរដែលលោកពូជឹម ចុន ជាប់ ព្រោះគាត់ជាអ្នកជាប់និន្នាការជាទាហាន ហើយក៏ជាប្រជាជនចាស់ដែរ ។ ជឹម ចុន បានជាប់នៅមន្ទីរគុណវិបត្តិអស់រយៈពេល៣-៤ខែចាប់ពីចុងឆ្នាំ១៩៧៤មកដល់ដើមឆ្នាំ១៩៧៥ បន្ទាប់ពីគាត់វិលត្រលប់មកពីខេត្តកំពង់ធំវិញ ។ លោកពូមានប្រសាសន៍ថា មន្ទីរនេះបានទទួលឲ្យចូលនូវមនុស្សដែលមានការបាត់បង់គ្រួសារ ដូចជាការសម្លាប់ ឬ ស្លាប់ដោយសារជម្ងឺ ។ លោកពូបញ្ជាក់ថា ប្រសិនបើប្តីត្រូវបានសម្លាប់ នោះពួកខ្មែរក្រហមបានយកប្រពន្ធមកដាក់នៅក្នុងមន្ទីរសន្តិសុខនេះក្នុង**ផ្នែកគុណវិបត្តិ** ។ ពុំសូវ មានការសម្លាប់មនុស្សប៉ុន្មានទេក្នុងផ្នែកនេះ ប៉ុន្តែក៏មានការសម្លាប់មនុស្សខ្លះដែរ ចំពោះអ្នកខ្ជិលច្រអូសនឹងការងារ, អ្នកលួចឆក់ជាដើម ។ ការងាររបស់លោកពូ ជឹម ចុន គឺលើកទំនប់ទាំងយប់ទាំងថ្ងៃពុំសូវមានពេលសំរាកឡើយ ។ ពួកខ្មែរក្រហមមិនសូវធ្វើទារុណកម្មទៅលើអ្នកជាប់នៅផ្នែកគុណវិបត្តិនេះទេ ព្រោះភាគច្រើនជាប្រជាជនចាស់ ។ ចំណែកឯប្រជាជនថ្មី (១៧មេសា) ដែលត្រូវបានយកមកដាក់នៅក្នុងមន្ទីរនេះដែរ ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ។ **ទួលតាសាំ** ជាទីតាំងសម្លាប់នៅភូមិចាស់ ឃុំដា ។ អ្នកទោសទាំងអស់នៅមន្ទីរភូមិចាស់ ត្រូវបានយកមកសម្លាប់នៅទួលតាសាំទាំងអស់ ។ ជឹម ចុន បានសន្និដ្ឋានថានៅទួលតាសាំនេះមានមនុស្សស្លាប់ពី១០០-១២០នាក់ និងមានរណ្តៅពី១៤-១៥រណ្តៅ ហើយក្នុងមួយរណ្តៅៗមានទំហំទទឹង១ម៉ែត្រ និង បណ្តោយពីម៉ែត្រកន្លះ ។ កន្លែងនេះស្ថិតនៅចំងាយប្រហែល១០០ម៉ែត្រពីមន្ទីរភូមិចាស់ ។ អ្នកស្លាប់ភាគច្រើនជាប្រជាជនថ្មី ប៉ុន្តែក៏មានលាយប្រជាជនចាស់ខ្លះដែរ ។ មុននឹងយកទៅសម្លាប់ អ្នកទោសទាំងអស់មិនបានទទួលនូវការកសាងទេ ។

*ដឹម ចុន បានប្រាប់ថាមេសន្តិសុខឈ្មោះ* ***ខេ ខឿន*** *សព្វថ្ងៃរស់នៅភូមិគុយ ឃុំដា ។* ***ខេ ខឿន*** *មិនបានសម្លាប់មនុស្សដោយផ្ទាល់ដៃទេ ប៉ុន្តែបានបញ្ជាឲ្យអ្នកក្រោមបង្គាប់យកមនុស្សទៅសម្លាប់ ។ ដឹម ចុន មិនត្រូវបានសម្លាប់នៅមន្ទីរចាស់ទេ ហើយក៏មិនអាចទទួលឲ្យស្នាក់នៅតទៅទៀតបាន ព្រោះគាត់និយាយថានៅមន្ទីរចាស់នេះ មិនអាចទទួលអ្នកទោសធ្ងន់ដូចរូបគាត់ ឲ្យនៅតទៅទៀតបាន ។ ដឹម ចុន ត្រូវបានពួកខ្មែរក្រហមបញ្ជូនបន្តទៅកាន់មន្ទីរសន្តិសុខមួយទៀតស្ថិតនៅក្នុងឃុំប្រណូក ស្រុកកំពង់លែងដើម្បីឲ្យសមនឹងទោសកំហុសជាទាហានកាលពីជំនាន់លន់ណុលនៃជីវិតរបស់គាត់ ។*

*២ -* ***<u>ឃុំប្រណូក</u>***

***<u>មន្ទីរសន្តិសុខវែង និង ទីតាំងសម្លាប់ភ្នំថ្មរៀង</u>***

*នៅដើមឆ្នាំ១៩៧៥, ដឹម ចុន បានមកជាប់នៅមន្ទីរសន្តិសុខភ្នំថ្មរៀង ដែលស្ថិតនៅក្នុងភូមិថ្មរៀង ឃុំប្រណូក ។ មន្ទីរនេះជាមន្ទីរឃុំឃាំង និងជាកន្លែងសម្លាប់យ៉ាងធំប្រចាំស្រុកកំពង់លែង ។ មន្ទីរសន្តិសុខនេះសង់ជាលក្ខណៈម៉ារីយេទាហានដែលមានទំហំទទឹង៥ម៉ែត្រ បណ្ដោយ២០ម៉ែត្រ ចំនួនពីរខ្នង និងមួយខ្នងទៀតមានទំហំទទឹង៥ម៉ែត្រ បណ្ដោយ៥០ម៉ែត្រ ។ អាគារខ្លីៗពីរខ្នងទល់មុខគ្នា (ទទឹង៥ម៉ែត្រ បណ្ដោយ២០ម៉ែត្រ) នេះធ្វើសំរាប់ដាក់តែកម្មាភិបាលខ្មែរក្រហមស្នាក់នៅ ។ ចំណែកឯអាគារមួយខ្នងវែងទៀត ដែលស្ថិតនៅជាប់នឹងអាគារខ្លីៗទាំងពីរនោះ សំរាប់ដាក់អ្នកទោសដែលមានគុណវិបត្តិ ។ នៅមានផ្ទះមួយខ្នងទៀតស្ថិតនៅខាងត្បូងអាគារទាំងបីខាងលើ សំរាប់ដាក់អ្នកទោសជាប្រជាជនថ្មី (១៧មេសា) រង់ចាំការយកទៅសម្លាប់ ។ ប្រធានសន្តិសុខនៅមន្ទីរវែងនោះមានឈ្មោះថា តាពាង (សព្វថ្ងៃស្លាប់) ។ ដឹម ចុន បានជាប់នៅមន្ទីរវែងអស់រយៈពេលជាងមួយឆ្នាំ ។ ការងារ របស់គាត់គ្មានអ្វីក្រៅពីធ្វើស្រែ, កាប់ព្រៃ និង កាប់ដើមឈើ......ៗល ។ ចំពោះការកាប់ដើមឈើនៅក្នុងស្រែ ពួកខ្មែរក្រហមហាមដាច់ខាតមិនឲ្យធ្លាក់ ឬ បាក់មែកឈើលើស្រូវឡើយ បើមិនដូច្នេះទេប្រាកដជាត្រូវយកទៅ សម្លាប់ហើយ ។*

*អ្នកទោសដែលបានប្រមូលមកដាក់នៅមន្ទីរនេះ ច្រើនតែជាប្រជាជន១៧មេសា និង យួន ។ តាមសំដីរបស់ ដឹម ចុន ថាអ្នកទោសទាំងនោះគ្មានកំហុសអ្វីឡើយ ហើយក្រោយពីបានមកដល់មន្ទីរនេះមិនដល់មួយយប់ផង ក៏ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ចោលអស់ ។ ពួកខ្មែរក្រហមធ្វើរបៀបនេះជារៀងរាល់ថ្ងៃ (បញ្ជូនចូលនៅម៉ោងប្រហែល៣រសៀល រួចបញ្ជូនចេញនៅពេលល្ងាច) ។ ដឹម ចុន បានបន្ថែមថា ប្រជាជន១៧មេសា, យួន, ទាហាន, អ្នកជាប់និន្នាការដែលពួកខ្មែរក្រហមបានប្រមូលយកមកកាន់មន្ទីរវែង គឺបានត្រឹមតែស្នាក់នៅ*

ក្រោមដើមឈើជាមួយបង្ខិចខោអាវសំពីងសំពោងជាប់នឹងខ្លួន ។ ប៉ុន្តែអ្នកទាំងនោះមិនត្រូវបានពួកខ្មែរក្រហមទុកឲ្យនៅយូរឡើយ គឺត្រូវបញ្ជូនទៅសម្លាប់អស់ ។ ប្រជាជនដែលបានបណ្តើរមកទីនេះ មានពី៧០-១០០នាក់ ។ ដឹម ចុន បាននិយាយថា នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៥, គាត់ត្រូវបានពួកខ្មែរក្រហមបណ្តើរឲ្យទៅភ្ជួរស្រែនៅជាប់នឹងជើងភ្នំថ្មរៀង ។ ពេលនោះទើបគាត់ដឹងថា ជាកន្លែងសម្លាប់មនុស្ស ព្រោះនៅពេលកំពុងភ្ជួរ គាត់បានប្រទះឃើញមានឆ្អឹង, ឈាម.........ពាសពេញដីនិងស្រែ ។ ដឹម ចុន បានប្រាប់ថាគាត់មានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំង តែមិនហ៊ានមាត់ឲ្យនរណាដឹង ។ ដឹម ចុន បានសន្និដ្ឋានថាប្រជាជនដែលគាត់បានឃើញនៅក្រោមដើមឈើក្នុងបរិវេណ**មន្ទីរសន្តិសុខវែង**កាលពីមុនៗ ប្រាកដជាត្រូវបានមកស្លាប់នៅតាម**ជើងភ្នំថ្មរៀង** និង តាម**វាលស្រែ** ដែលស្ថិតនៅភូមិថ្មរៀង ឃុំប្រណូក ស្រុកកំពង់លែងនេះ ព្រោះគាត់ឃើញមានរណ្តៅធំៗជាច្រើនព្រមទាំងមានសាកសពពេញ ។

ចំណែករណ្តៅសាកសពវិញ ដឹម ចុន បានប្រាប់ថាមានរាប់រយរណ្តៅ (ទាំងធំ-តូច) នៅជុំវិញភ្នំថ្មរៀង ជាពិសេសស្ថិតនៅខាងជើងជើងភ្នំ, ខាងត្បូងជើងភ្នំ និង ខាងកើតជើងភ្នំ ព្រមទាំងនៅតាមវាលស្រែដែលមានចំងាយ៥០-៦០ម៉ែត្រពីជើងភ្នំថ្មរៀងទៀត ។

ដឹម ចុន ថានៅតាមជើងភ្នំថ្មរៀង រណ្តៅតូចបំផុតមានទំហំទទឹង២ម៉ែត្រ បណ្តោយ១០ម៉ែត្រ និង រណ្តៅធំបំផុតមានទំហំទទឹង២០ម៉ែត្រ បណ្តោយ៣០ម៉ែត្រ ដែលមានជំរៅប្រហែល១ម៉ែត្រ ។សាកសពដែលបានស្លាប់នៅទីនោះ (ទាំងខាងជើងជើងភ្នំ, ខាងត្បូងជើងភ្នំ និង ខាងកើតជើងភ្នំ) មានប្រហែល**ជាងមួយម៉ឺននាក់** ។ ចំណែកឯនៅតាមវាលស្រែវិញ លោកពូ ដឹម ចុន បានប្រាប់ថាក្នុងស្រែមួយៗ ពួកខ្មែរក្រហមបានជីករណ្តៅជា៤មុំតាមជ្រុងស្រែ ដើម្បីកប់សាកសពធ្វើជី ។ សាកសពដែលដាក់ក្នុងរណ្តៅមួយៗមានពី៥-៦នាក់ ។

នៅវេលាម៉ោង១៦:០០ ក្រុមស្រាវជ្រាវបានធ្វើដំណើរមកជួបលោកតា លៀន លូ ព្រមទាំងមានការជូនដំណើពីលោកមេឃុំ **ដឹម ចាន់** ផង ។ លោកតាអាយុ៧៤ឆ្នាំ មានទីលំនៅទាំងបីជំនាន់រស់នៅភូមិធ្លក ឃុំប្រណូក ស្រុកកំពង់លែង ។ លោកតាបានជាប់នៅក្នុងមន្ទីរវែងតាំងពីឆ្នាំ១៩៧៣មក ព្រោះគាត់ត្រូវបានពួកខ្មែរក្រហមចោទប្រកាន់ជានាយទុន ។ អ្វីដែលលោកតាបាននិយាយ មិនខុសពីអ្វីដែលលោកមេឃុំបាននិយាយទេ ប៉ុន្តែលោកតាបានបញ្ជាក់បន្ថែមថា ចំពោះការហូបចុកគឺពួកខ្មែរក្រហមឲ្យបរិភោគគ្មានអ្វីក្រៅពីបបរបីវែកលាយជាមួយត្រកួនទាំងឬស ទាំងដើម ។ ចំណែកការងាររបស់គាត់គឺភ្ជួររាស់, រកអុស, កាប់ដីដំបូក ។ លោកតាបានឃើញមានគល់ឬស្សីពីងពុង, រណ្តៅសាកសពសុទ្ធតែឈាមពេញរណ្តៅ នៅពេលដែលគាត់ត្រូវបានពួកខ្មែរក្រហមបញ្ជូនឲ្យមកធ្វើស្រែនៅខាងជើងភ្នំ ។ លៀន លូ បាននិយាយថាមុននឹងពួកខ្មែរក្រហមយកប្រជាជនមកដល់មន្ទីរ

វែង គឺពួកខ្មែរក្រហមបានយកមកដាក់នៅសហករណ៍ភូមិធ្លកសិន ។ លោកតា បានរួចខ្លួនពីការសម្លាប់ព្រោះគាត់ពេលនោះសកម្មការងារ ។

ចំពោះចំនួនសាកសព និង រណ្តៅសាកសព លោកតា លៀន លូ បានប្រាប់ដូចលោកមេឃុំប្រាប់ដែរ ។

<u>មន្ទីរសន្តិសុខ និង ទីតាំងសម្លាប់នៅភ្នំកង្កែប</u>

ភ្នំកង្កែបស្ថិតនៅក្នុងភូមិថ្នកង្កែប ឃុំប្រណូក ស្រុកកំពង់លែង ។ ទីតាំងនេះជាទីតាំងសម្លាប់ធំបន្ទាប់ពីមន្ទីរវែង ។ តាមសំដីរបស់ ដឹម ចុន ដដែលថាមនុស្សដែលបានយកមកស្តុបបណ្តោះអាសន្ននៅភ្នំកង្កែបនេះស្ថិតនៅលើសាលាឆទានមួយហៅថា ***សាលាឆទានភ្នំកង្កែប*** ដែលស្ថិតនៅជាប់ខាងលិចជើងភ្នំកង្កែប ។ បន្ទាប់មកក៏ត្រូវយកទៅសម្លាប់នៅខាងជើងភ្នំកង្កែបប្រហែល៧០ម៉ែត្រពីគ្នា ។ ដឹម ចុន បញ្ជាក់ថាមនុស្សដែលយកមកដាក់នៅភ្នំកង្កែបនេះ ត្រូវបានបញ្ជូនមកពីមន្ទីរវែងនៃភ្នំថ្មរៀង ព្រោះកាលនោះពួកខ្មែរក្រហមធ្វើការសម្លាប់មិនទាន់នៅភ្នំថ្មរៀង ក៏បញ្ជូនមកសម្លាប់នៅភ្នំកង្កែបបន្ថែម ដើម្បីឲ្យទាន់ផែនការ ។ ប្រជាជនដែលត្រូវយកមកសម្លាប់នៅភ្នំកង្កែបនេះមិនត្រូវបានទុកយូរឡើយ ប្រមាណតែ៣-៤ម៉ោងប៉ុណ្ណោះ ។ រយៈពេលសម្លាប់មនុស្សនៅភ្នំកង្កែបនេះមានចំនួនតែ១៥ថ្ងៃគត់ ។ ចំនួនសាកសពសរុបប្រមាណពី៤០០០-៥០០០**នាក់** ។ ជនរងគ្រោះច្រើនតែជាប្រជាជនថ្មី (១៧មេសា) ។ មន្ទីរភ្នំកង្កែបនេះក៏គ្រប់គ្រងដោយប្រធានសន្តិសុខឈ្មោះ ***តាពាង*** ដែរ ។ ចំណែករណ្តៅសាកសពវិញ ដឹម ចុនប្រាប់ថាមានចំនួនពី១៤-១៥រណ្តៅ ដែលមានទំហំទទឹង៨ម៉ែត្របណ្តោយ ១២ម៉ែត្រ ។ មន្ទីរនេះស្ថិតនៅចំងាយប្រហែល១គីឡូម៉ែត្រពីមន្ទីរវែង ។ ទីតាំងសម្គាល់បច្ចុប្បន្ន មានដើមស្វាយ ដើមពោធិជាសម្គាល់ ។

៣-<u>ឃុំតានឹល</u>

<u>មន្ទីរសន្តិសុខភូមិឡាបាន</u>

មន្ទីរនេះ ក្រុមស្រាវជ្រាវយើងបានចុះទៅដល់និងធ្វើការសិក្សាស្រាវជ្រាវម្តងរួចហើយ ប៉ុន្តែនៅពេលនេះក្រុមស្រាវជ្រាវយើងបានសួរបញ្ជាក់បន្ថែមខ្លះៗពីលោក ដឹម ចុន ព្រោះកាលពីជំនាន់ប៉ុលពតគាត់ធ្លាប់ជាប់នៅមន្ទីរសន្តិសុខឡាបាន បន្ទាប់ពីចេញពីមន្ទីរវែង ។

នៅដើមឆ្នាំ១៩៧៧ លោកពូដឹម ចុន ត្រូវបានដោះលែងឲ្យរួចខ្លួនពីមន្ទីរវែង ដោយសារគាត់មានការងារល្អ ធ្វើឲ្យពួកខ្មែរក្រហមមានការពេញចិត្តនឹងការងាររបស់គាត់ ។ ក្រោយពីចេញពីមន្ទីរវែង គាត់បានទៅ

ធ្វើជាកងចល័តនៅ**ការដ្ឋានព្រែកចង្កៀង** និងបន្ទាប់មក មកនៅ**ការដ្ឋានគោករំដួល** (ខាងលិចព្រៃខ្មែរ ខេត្តកំពង់ ឆ្នាំង) ។ រយៈពេលជាងមួយឆ្នាំក្រោយមក លោកពូជីម ចុន ត្រូវបានពួកខ្មែរក្រហមចាប់ខ្លួនម្តងទៀត ហើយ យកទៅដាក់នៅមន្ទីរសន្តិសុខឡាបាននៅថ្ងៃ១៣ ខែឧសភា ឆ្នាំ១៩៧៨ ។ មូលហេតុនៃការចាប់ខ្លួន លោកពូជីម ចុនបានប្រាប់ថា គឺពួកខ្មែរក្រហមស៊ើបដឹងថាគាត់ធ្លាប់ធ្វើទាហានកាលពីជំនាន់លន់ណុល ។

មន្ទីរនេះស្ថិតនៅភូមិឡាបាន ឃុំតាងិល ស្រុកកំពង់លែង ។ ជីម ចុន បានជាប់នៅក្នុងមន្ទីរឡាបានតែ រយៈពេល៩ថ្ងៃប៉ុណ្ណោះ ក៏ត្រូវដោះលែងមកវិញ ដោយមានការដោះលែងពី**មិត្ត អាត** (បច្ចុប្បន្នស្លាប់) ដែល ជាកម្មាភិបាលខ្មែរក្រហមម្នាក់នៅខេត្តកំពង់ឆ្នាំង ។ ជីម ចុន បានប្រាប់ថា គាត់មានក្មួយម្នាក់ឈ្មោះ **បេង ចាន់** (បច្ចុប្បន្នស្លាប់) ជានិរសាររបស់**មិត្ត អាត** ។ ដោយដឹងថា គាត់ជាប់នៅមន្ទីរសន្តិសុខលាបាន **បេង ចាន់** ក៏បានរាយការណ៍ប្រាប់**មិត្ត អាត**, សុះមួយថ្ងៃក្រោយមក មិត្ត **អាត**ក៏បានមកដោះលែងជីម ចុន ឲ្យទៅរស់ នៅជាមួយប្រពន្ធវិញ ។

ក្នុងរយៈពេល៩ថ្ងៃ នៅក្នុងមន្ទីរឡាបាន ជីម ចុន បានប្រាប់ថាគាត់ត្រូវបានពួកខ្មែរក្រហមវាយសន្លប់ បីដងក្នុងមួយថ្ងៃ ។ អ្នកជាប់នៅទីនោះ រួមទាំងគាត់ផង សុទ្ធតែត្រូវដាក់ច្រវ៉ាក់ក ពីរជាន់, ដាក់ខ្នោះជើង, ចង ស្លាបសេក ។ នៅក្នុងមន្ទីរនោះ គាត់មិនបានដេកទេ ព្រមទាំងមិនបានបរិភោគអាហារទៀត ។ មិនតែប៉ណ្ណោះ ពួកខ្មែរក្រហមបានដាក់បទបញ្ជារ៤០ប្រការឲ្យអ្នកទោសទាំងអស់ទន្ទេញ ។ វិន័យទាំង៤០ ប្រការនេះជីម ចុន មិនបាននៅចាំទាំងអស់ទេ ប៉ុន្តែគាត់បានប្រាប់យើងបានត្រឹមតែ១១ប្រការប៉ុណ្ណោះគឺៈ

១ - ទះមូស ក៏ត្រូវសុំអង្គការ

២ - ចង់ងើបអង្គុយត្រង់ខ្លួន ក៏ត្រូវសុំអង្គការ

៣ - ចង់អេះរមាស់ ក៏ត្រូវសុំអង្គការ

៤ - ស្រេកទឹក ក៏ត្រូវសុំអង្គការ

៥ - ចង់បត់ជើង ក៏ត្រូវសុំអង្គការ

៦ - ចង់នោម ក៏ត្រូវសុំអង្គការ

៧ - ចង់ដេក ក៏ត្រូវសុំអង្គការ

៨ - ចង់ប្រែខ្លួន ក៏ត្រូវសុំអង្គការ

៩ - កុំឲ្យឮច្រវ៉ាក់ដាក់ក

១០ - កុំឲ្យជជែកគ្នា

១១-ពេលវេីកុំឲ្យស្រែក

វិន័យទាំង៤០ដែលបានដាក់មិនត្រូវបានអនុវត្តន៍ទេ ។ ប្រសិនបើអ្នកទោសណាហ៊ានសុំតាមបទបញ្ជារដែលបានដាក់គឺ ប្រាកដជាត្រូវពួកខ្មែរក្រហមដែលយាមនោះ វាយធ្វើបាបមិនខាន ។ ដឹម ចុន បានប្រាប់បន្តថាទោះធ្វើតាមបទបញ្ជារក៏វាយ ទោះមិនធ្វើតាមក៏វាយដែរ ព្រោះជាការរំខានដល់ការងាររបស់ពួកខ្មែរក្រហម ។ ដឹម ចុន បានឃើញផ្ទាល់នូវការធ្វើទារុណកម្មទៅលើតាពីរនាក់ បន្ទាប់ពីគាត់ទាំងពីរស្រែកឈឺនូវការចុកចាប់ក្នុងខ្លួនខ្លាំងពេក ។ ខ្មែរក្រហមបានយកពូថៅទៅវាយលើពោះតាទាំងពីរនោះរហូតដល់សន្លប់ ទើបយកខ្សែនីឡុងប៉ុនកូនដៃចងទំលាក់តាមកាំជណ្តើរ ដោយដាក់ក្បាលសំយ៉ុងចុះ រួចក៏ស្រាយខ្សែដែលចងនោះចេញ ទើបទំលាក់តាទាំងពីរនោះតាមជណ្តើរពីលើរហូតដល់ក្រោម បន្ទាប់មកខ្មែរក្រហមក៏យកតាទាំងពីរនោះទៅកប់ចោលទៅ ។ ចំពោះអ្នកដែលខុសសីលធម៌វិញ គឺត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោល បន្ទាប់ពីមានការធ្វើទារុណកម្មរួចមក ។ ទារុណកម្មដែលពួកខ្មែរក្រហមបានធ្វើនោះគឺយកស្រីដែលខុសសីលធម៌នោះមកឲ្យដេកស្រាត រួចពួកខ្មែរក្រហមយកគ្រាប់កាំភ្លើង (៧៩) មកដោតឲ្យចំកេរ្តិ៍ខ្មាស់របស់ស្ត្រីនោះ បន្ទាប់មកពួកខ្មែរក្រហមចាប់ផ្តើមដុតកៅស៊ូកង់សំរក់ពីលើ ហើយក៏យកស្ត្រីនោះទៅដុតទាំងរស់ដោយបានចងភ្ជាប់ជាមួយបុរសដែលស្ត្រីនោះបានខុសសីលធម៌ជាមួយ ។

មេសន្តិសុខនៅមន្ទីរឡាបានឈ្មោះ **ទុន** (បច្ចុប្បន្នស្លាប់) ។ អ្នកទោសទាំងអស់បានទទួលរបបអាហារប្រចាំថ្ងៃនូវពោតលីងតែ១៥គ្រាប់ប៉ុណ្ណោះ ។ ក្នុងរយៈពេល៥ថ្ងៃដែល ដឹម ចុន បានរស់នៅក្នុងមន្ទីរឡាបានគាត់បានឃើញផ្ទាល់ភ្នែកថាមានមនុស្សស្លាប់ជាង១០០នាក់នៅនឹងមន្ទីរសន្តិសុខឡាបាននេះ ។ ចំពោះរណ្តៅសាកសពគាត់មិនបានដឹងឡើយ ។

៤-<u>ឃុំស្វាយរំពារ</u> <u>(ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០០)</u>

វេលាម៉ោង៧:០០ព្រឹក, ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរទៅកាន់ឃុំស្វាយរំពារដើម្បីទៅពិនិត្យទីតាំងមួយចំនួនដូចជា ទីតាំងភ្នំរងៀង, ដីរីកប់កូន និង ប្រណុកកុ្តល ក៏ដូចជាស្វែងរកជួបអ្នកដែលបានដឹងឮមួយចំនួនដែលស្ថិតនៅក្បែរទីតាំងនោះ ។ ពេលទៅដល់ក្រុមយើងបានជួបជាមួយលោកតាម្នាក់ដែលកំពុងតែពិសារនំបញ្ចុកនៅតាមដងផ្លូវលំមួយខ្សែដែលលាតសន្ធឹងពីសាលាស្រុកកំពង់លែងទៅឃុំប្រណូក ហើយក៏ស្ថិតនៅជាប់នឹងសាលាឃុំស្វាយរំពារដែរ ។ ក្រោយពីការសាកសួរពត៌មានខ្លះរួចមកទើបយើងដឹងថាទីតាំងដែលក្រុមយើងបំរុងនឹងចុះទៅ

*ដល់ទាំងបីខាងលើគឺ ភ្នំរងៀង, ដីរីកប៉ូន និង ប្រណុកគ្គុល ពុំមានទីតាំងសម្លាប់មនុស្ស ឬ មន្ទីរសន្តិសុខរបស់ខ្មែរក្រហមឡើយ ។*

*លោកតានោះមានឈ្មោះថា អ៊ុំ អាង អាយុ៨១ឆ្នាំ មានទីលំនៅបច្ចុប្បន្នរស់នៅភូមិល្ហា ឃុំស្វាយរំពារ ស្រុកកំពង់លែង ។ ទាំងបីជំនាន់លោកតានៅតែរស់នៅទីនេះដដែល ។ លោកតាបានរៀបរាប់ថា ប្រជាជនដែលបានបញ្ជូនពីស្ទឹងដើងគ្រួសមក គឺត្រូវឲ្យមកធ្វើការងារនៅមន្ទីរកំពង់ពាលស្វារ ។ ក្រោយមកប្រជាជនទាំងនោះត្រូវបានបញ្ជូនមកកាន់វត្តស្វាយរំពារខ្លះ ទៅកាន់ភ្នំរងៀងខ្លះ ។ បន្ទាប់មកពួកខ្មែរក្រហមក៏យកអ្នកដែលជាប់និន្នាការទៅដាក់នៅកន្លែង**ទួលគោកស្រុក**ដើម្បីត្រៀមយកទៅសម្លាប់ ។ **ទួលគោកស្រុក**ស្ថិតនៅភូមិក្នុង ឃុំស្វាយរំពារ ។ តាមសំដីរបស់លោកតា **អ៊ុំ អាង** ថា ព្រឹត្តិការណ៍បានកើតឡើងនៅឆ្នាំ១៩៧៥ ។ ចំពោះអ្នកដែលបានមកដល់ទួលគោកស្រុកនេះ គឺមិនបានរយៈពេលមួយថ្ងៃផង ក៏ត្រូវសម្លាប់ចោលអស់ ។ កាលនោះលោកតាត្រូវបានពួកខ្មែរក្រហមប្រើឲ្យទៅភ្ជួរ ។ ដោយបានដំណឹងពីមិត្តភក្រ្តគាត់ម្នាក់ឈ្មោះ **អួន** ប្រាប់ថាក្រោយពីភ្ជួររួចគឺប្រាកដជាត្រូវទៅកប់ខ្មោចហើយ ។ ពេលនោះ លោកតាបានប្រកែកមិនព្រមទៅភ្ជួរ ហើយបន្ទាប់មកគាត់ក៏ត្រូវបានចាត់តាំងឲ្យទៅចាំចាបនៅឯស្រែជាប់នឹងកន្លែងកប់ខ្មោចដែរ ។ កន្លែងចាំចាបនោះ ឈ្មោះថា **ប៉ាំដាញ** ។ កន្លែងនេះមានសុទ្ធតែព្រៃក្រាស់ៗ ប៉ុន្តែស្ថិតនៅក្នុងភូមិក្នុង ឃុំស្វាយរំពារ ។*

*លោកតាបានបន្ថែមថា នៅឃុំស្វាយរំពារនេះមានទីតាំងសម្លាប់ពីរកន្លែងគឺៈ ទីមួយ នៅត្រពាំងតាឃ្លោក និង ទីពីរ នៅត្រពាំងអារ៉ែងកំពួច ដែលស្ថិតនៅជាប់នឹងកន្លែងចាំចាបដែលលោកតាបានរៀបរាប់ខាងលើ ។*

***<u>ទីតាំងត្រពាំងតាឃ្លោក</u>***

*យោងតាមសំដីរបស់លោកតា អ៊ុំ អាង ថាមានចំនួនប្រហែល៤០រណ្តៅ ហើយក្នុងមួយរណ្តៅៗ មានទំហំទទឹង២ម៉ែត្រ បណ្តោយ៣ម៉ែត្រ ។ ចំនួនសាកសព,លោកតាបានប៉ាន់ស្មានថាមានចំនួនពី១៥០-២០០នាក់ ។ ត្រពាំងតាឃ្លោក ស្ថិតនៅខាងត្បូងទីតាំងមន្ទីរសន្តិសុខទួលគោកស្រុក ហើយក៏ស្ថិតនៅក្នុងភូមិក្នុង ឃុំស្វាយរំពារ ស្រុកកំពង់លែងដែរ ។*

***<u>ទីតាំងបឹងអារ៉ែងកំពួច</u>***

*លោកតាបានមានប្រសាសន៍ថា ពួកខ្មែរក្រហមបានយកជនរងគ្រោះពីខាងស្ទឹងព្រែកគ្រួសតាមទូកមកឡើងលើទួលបឹងអារ៉ែងកំពួចនេះ ដើម្បីចំរាញ់ប្រវត្តិរូបជនរងគ្រោះទាំងនោះយកទៅសម្លាប់នៅក្បែរៗទំនប់បឹងនេះ ។ ការចំរាញ់ប្រវត្តិរូបរបស់ពួកខ្មែរក្រហមនាពេលនោះគឺជ្រើសរើសយកអ្នកដែលជាប់និន្នាការ, ធ្លាប់ធ្វើទាហាន.........ជាដើម ។ ជនរងគ្រោះដែលដឹកតាមទូកមកនេះមានចំនួនប្រហែល២០០ទូក ។ លោកតាបានប្រាប់*

បន្តថា សាកសពទាំងនោះត្រូវបានពួកខ្មែរក្រហមកប់នៅតាមបណ្តោយផ្លូវថ្នល់មួយដែលមានប្រវែងប្រហែល ៣ គីឡូម៉ែត្រ និង ទទឹងប្រហែល៨ម៉ែត្រ ។ ផ្លូវថ្នល់នេះ មិនមែនជាផ្លូវសំរាប់ធ្វើដំណើររបស់ប្រជាជនទេ គឺជាទំនប់ទឹកមួយដ៏ធំនៅបឹងអារ៉ែងកំពូចនេះ ។ ប៉ុន្តែសព្វថ្ងៃយើងសង្កេតឃើញមានផ្ទះរបស់ប្រជាជនមួយចំនួននៅជាប់នឹងជងផ្លូវនេះ ព្រោះជាលក្ខណៈមួយងាយស្រួលក្នុងការនេសាទត្រី ។ ការសម្លាប់ប្រជាជននៅទីនេះ ធ្វើឡើងនៅឆ្នាំ១៩៧៥ ច្រើនតែជាប្រជាជនជម្លៀសដឹកតាមទូក ។ ទីតាំងនេះស្ថិតនៅខាងត្បូងវត្តស្វាយរំពារ ប្រហែលជាង ១គីឡូម៉ែត្រ ។ លោកតាបានធ្វើការប៉ាន់ស្មានអ្នកស្លាប់ថាមានចំនួនប្រហែល៨០-១០០នាក់ ។ ពួកខ្មែរក្រហមសម្លាប់ភាគច្រើនជាប្រុសៗដែលជាប់និន្នាការ ។ ជាចុងក្រោយលោកតាបានប្រាប់ថា គ្មានលក្ខណៈជារណ្តៅទេ គឺសាកសពច្រើនតែស្ថិតនៅជាលក្ខណៈរាយប៉ាយ ។

__សន្និដ្ឋាន__

ក្នុងស្រុកកំពង់លែងនេះ យើងបានចុះទៅដល់ទីតាំងធំៗមួយចំនួនដូចជា មន្ទីរសន្តិសុខវែង និង ទីតាំងសម្លាប់នៅតាមជើងភ្នំថ្មរៀងដែលស្ថិតនៅក្នុងភូមិថ្មរៀង ឃុំប្រណួក ។ យោងតាមសំដីរបស់អ្នកដែលបានដឹងព្ទមួយចំនួនដូចបានរៀបរាប់ខាងលើ បានឲ្យដឹងថា មានការសម្លាប់មនុស្សយ៉ាងច្រើនរហូតដល់ទៅរាប់ម៉ឺននាក់ ។ អ្នកដែលបានស្លាប់នៅក្នុងស្រុកកំពង់លែងភាគច្រើនៗជាប្រជាជនថ្មីដែលត្រូវបានជម្លៀសចេញពីកន្លែងផ្សេងៗ ក្នុងខេត្ត ក៏ដូចជាតាមបណ្តាខេត្ត-ក្រុងនានា ។ ចំណែកឯ**មន្ទីរសន្តិសុខវែងវិញ** មានបែងចែកជាពីរប្រភេទទៀតគឺ មួយសំរាប់ដាក់**អ្នកដែលមានគុណវិបត្តិ** (មន្ទីរនេះជាមន្ទីរសំរាប់កសាងអ្នកដែលមានគុណវិបត្តិ ដូចជាត្រូវពួកខ្មែរ ក្រហមយកប្តី ឬ ប្រពន្ធទៅសម្លាប់, ប្រជាជនចាស់ដែលជាប់និន្នាការជាទាហាន...... ។ល ។) និងមួយផ្នែកទៀតសំរាប់ស្តុបប្រជាជនថ្មីមុនយកទៅសម្លាប់ ។ មិនតែប៉ុណ្ណោះក៏មានការសម្លាប់ជាទ្រង់ទ្រាយធំមួយកន្លែងទៀតរហូតដល់ទៅពី៤០០០-៥០០០នាក់តែក្នុងរយៈពេល១៥ថ្ងៃ ។ កន្លែងនោះមានឈ្មោះថា **ភ្នំកន្តែប** ។ ភ្នំកន្តែបនេះជាសាខារបស់ទីតាំងភ្នំថ្មរៀង ព្រោះថាពេលណានៅភ្នំថ្មរៀងមានការសម្លាប់មិនទាន់តាមផែនការរបស់ **តាពាង** ដែលជាប្រធានសន្តិសុខនៅភ្នំថ្មរៀង និង នៅភ្នំកន្តែប, នោះប្រាកដជាត្រូវបញ្ជូនជនរងគ្រោះមួយចំនួនមកកាន់ភ្នំកន្តែបនេះ ដើម្បីសម្លាប់បង្គ្រប់ផែនការ ។ ទីតាំងទាំងពីរនេះស្ថិតនៅចំងាយប្រហែលមួយគីឡូម៉ែត្រពីគ្នា ។

ចំណែកឯនៅមន្ទីរសន្តិសុខភូមិចាស់, កន្លែងសម្លាប់ទួលតាសាំ និងកន្លែងសម្លាប់ពីរកន្លែងទៀតនៅក្នុងឃុំស្វាយរំពារ ក៏មានការសម្លាប់ច្រើនតែជាប្រជាជន១៧មេសាដែរ ប៉ុន្តែមិនមានជាលក្ខណៈធំប៉ុន្មានទេ ។

<u>ស្រុកជលគីរី</u>

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០០ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរបន្តទៅកាន់ស្រុកជលគីរី ដើម្បីធ្វើការស្រាវជ្រាវទៅលើទីតាំងមួយចំនួនដែលមានការសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហមកាន់អំណាច ។ ក្រុមយើងបានធ្វើដំណើរតាមទូកមួយគ្រឿងពីស្រុកកំពង់លែងឆ្ពោះទៅកាន់ស្រុកជលគីរី ដោយចំណាយពេលវេលាអស់៤៥នាទី ។ ទៅដល់ទីនោះ ក្រុមយើងបានជួបជាមួយលោកមេឃុំឈ្មោះ កែ ម៉េត អាយុ៥១ឆ្នាំ ។ គាត់រស់នៅភូមិពាមឆ្កោក ឃុំពាមឆ្កោក ស្រុកជលគីរី ។ លោកមេឃុំបានប្រាប់ថា កាលពីជំនាន់ខ្មែរក្រហមនៅស្រុកជលគីរីនេះ ជាពិសេសនៅឃុំពាមឆ្កោក ពុំមានការសម្លាប់មនុស្សច្រើនទេ ព្រោះទាំងប្រជាជនថ្មី (១៧មេសា) ប្រជាជនចាស់មួយចំនួន ត្រូវបានបញ្ជូនទៅកាន់ស្រុកកំពង់លែង ដើម្បីចូលធ្វើជាក្រុមសហករណ៍ ។ លោកមេឃុំរូបនោះបានប្រាប់បន្តថា ព្រែកអញ្ចាញ និង ព្រែកប្រណាក មានការសម្លាប់មនុស្សតិចតួចបំផុតគឺ ចំនួនពីរនាក់ប៉ុណ្ណោះ ។ មូលហេតុដែលបណ្តាលឲ្យអ្នកទាំងពីរនោះស្លាប់ តាមសំដីរបស់លោកមេឃុំថា បានធ្វើខុសនឹងការហាមឃាត់របស់ខ្មែរក្រហមចំពោះការធ្វើដំណើរឆ្លងកាត់ដោយគ្មានការអនុញ្ញាត ។ ចំងាយពីសាលាឃុំពាមឆ្កោកទៅកាន់ទីតាំងព្រែកអញ្ចាញ និង ព្រែកប្រណាក ប្រហែល៨-៩គីឡូម៉ែត្រ ហើយធ្វើដំណើរតាមទូកទៀត ។ ព្រែកអញ្ចាញ និង ព្រែកប្រណាក ស្ថិតនៅក្នុងភូមិក្បាលកន្ធង់ ឃុំពាមឆ្កោក ។

ក្រុមយើងមិនបានចុះទៅដល់ទីតាំងទាំងពីរខាងលើទេ ព្រោះមិនមែនទីតាំងសម្លាប់ ឬ ជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមឡើយ ។ ម្យ៉ាងយើងពិបាកធ្វើដំណើរតាមផ្លូវទឹកទៅដល់កន្លែងនោះ ។

យើងបានចាកចេញពីឃុំពាមឆ្កោកឆ្ពោះមកកាន់ឃុំព្រែកគ្រី ។ នៅទីនោះ យើងបានជួបជាមួយលោកតាម្នាក់ឈ្មោះ អួន ទឹម អាយុ៦២ឆ្នាំ ។ ទីលំនៅទាំងបីជំនាន់លោកតារស់នៅឃុំព្រែកគ្រី ស្រុកជលគីរី ។ កាលពីជំនាន់ប៉ុលពត លោកតាជាប្រធានកងហារនៅភូមិព្រែកគ្រីជើង ។ លោកតាបានប្រាប់ថាគណៈឃុំព្រែកគ្រីឈ្មោះ ទុយបានស្រង់ស្ថិតិប្រជាជនក្នុងឃុំឲ្យទៅខាងផ្នែកយោធាស្រុកដើម្បីយកទៅសម្លាប់ ។ ប៉ុន្តែលោកតាមិនបានដឹងច្បាស់ថាតើនរណាជាអ្នកសម្លាប់ផ្ទាល់ដៃ ។ យោងតាមសំដីរបស់លោកតាថា គ្មានការសម្លាប់មនុស្សនៅឃុំព្រែកគ្រីទេជាពិសេសនៅ **ពោធិពូនភ្នំ** ។ លោកតាបានបញ្ជាក់ថានៅតំបន់ពោធិពោនភ្នំនេះមានការសម្លាប់ទាហានលន់ណុល ដែលមកវាយនៅបន្ទាយព្រែកគ្រី

តាំងពីជំនាន់លន់ណុលម្ល េះ ។ ចំពោះប្រជាជនថ្មី ព្រមទាំងអ្នកដែលមានកំហុស លោកតាបានប្រាប់ថា ត្រូវពួកខ្មែរក្រហមបញ្ជូនទៅកាន់ស្រុកកំពង់លែង ព្រោះកាលពីជំនាន់ប៉ុលពតឃុំព្រៃគ្រី ស្ថិតនៅក្នុងស្រុកកំពង់លែង ។

ក្រោយពីបានជួបជាមួយលោកតារូបនោះរួច ក្រុមយើងបានជួបជាមួយលោកពូប្រធានភូមិឈ្មោះ យុត សុខ អាយុ៤៣ឆ្នាំ មានស្រុកកំណើតនិងបច្ចុប្បន្នរស់នៅភូមិព្រៃគ្រី ឃុំព្រៃគ្រី ស្រុកជលគិរី ។ ជំនាន់ប៉ុលពតក៏រស់នៅទីនេះដែរ ។ លោកពូបានរៀបរាប់ថា កាលពីនៅឃ្វាលគោជំនាន់ប៉ុលពតនៅពោធិពូនភ្នំ លើផ្លូវព្រះរាមបានធំក្លិនស្អុយ រួចក៏បានដើរចូលទៅមើល ក៏ឃើញខ្មោចកប់ដីថ្មីៗ ព្រមទាំងមានឈាមទៀត ។ លោកពូបានឃើញនៅក្នុងឆ្នាំ១៩៧៦ ។ ពេលនោះលោកពូបានឮចាស់ៗក្នុងភូមិនិយាយថាសាកសពដែលបានស្លាប់នៅកន្លែងនោះ ភាគច្រើនជាប្រជាជនថ្មីដែលត្រូវបានជន្លៀសចេញពីទីក្រុងភ្នំពេញមក ។ មានការសម្លាប់ទាំងគ្រួសារៗ ។ ទីតាំងសម្លាប់មនុស្សខាងលើមានឈ្មោះថា **ថ្នល់ព្រះរាម** ។ ការសម្លាប់មនុស្សនាពេលនោះ (១៩៧៥-៧៩) គឺ តាមបណ្តោយថ្នល់ព្រះរាមរហូតដល់ពោធិពូនភ្នំ ។ ចំងាយប្រហែលមួយគីឡូម៉ែត្រ ។ លោកពូបានប៉ាន់ស្មានថា មានប្រមាណពី៧-៨រណ្តៅ (គ្រាន់តែរាប់នៅជាប់ៗថ្នល់ព្រះរាម មិនគិតពីរណ្តៅដែលនៅខាងក្នុងព្រៃតាមអមសងខាងថ្នល់ព្រះរាម) ។ ចំនួនសាកសពរួមមានពី៣០-៤០នាក់ ។ ចំពោះការសម្លាប់នៅជួរថ្នល់ព្រះរាមនេះ មិនមែនសម្លាប់ទូទៅទេ គឺសម្លាប់របៀបចំរាញ់យកអ្នកជាប់និន្នាការពីសង្គម និង អ្នកធ្លាប់ធ្វើទាហានសម័យលន់ណុល ។ ការសម្លាប់មនុស្សមិនប្រាកដថាពេលណាទេ ជួនកាលពេលថ្ងៃ ជួនកាលពេលយប់ ។ លោកពូធ្លាប់បានឃើញពួកខ្មែរក្រហមបណ្តើរអ្នកទោសកាត់តាមភូមិ,សហករណ៍មកសម្លាប់ ដោយមានចងអ្នកទោសទាំងនោះផង ។ អ្នកបណ្តើរអ្នកទោស មានគ្នាពីរនាក់ ស្លៀកពាក់ជាឯកសណ្ឋានជាហានខ្មែរក្រហម ។ វិធីសម្លាប់របស់ពួកខ្មែរក្រហមនាពេលនោះគឺ ប្រើដំបង និង ជំពុះទុងចាក់តែម្តង ។ ទីតាំងនេះ ស្ថិតនៅក្នុងភូមិ ព្រៃគ្រីជើង ឃុំព្រៃគ្រី ស្រុកជលគិរី ។

នៅថ្ងៃដដែលនោះ ក្រុមយើងបានបន្តដំណើរទៅកាន់ឃុំមួយទៀតដែលស្ថិតនៅក្នុងស្រុកជលគិរីដែរ ។ ឃុំនេះគឺ ឃុំជលសារ ។ គោលបំណងរបស់ក្រុមយើងគឺ ចង់ទៅពិនិត្យដល់ទីតាំងមួយឈ្មោះថា **កំពង់បាស្រូវ** ។ យោងតាមរបាយការណ៍ពីមន្ទីរស្រុកកំពង់លែងថា កំពង់បាស្រូវនេះ ជាទីតាំងសម្លាប់មួយកន្លែងក្នុងឃុំជលសារ ។ ជាក់ស្តែងយើងបានចុះទៅដល់ឃុំជលសារនៅម៉ោង១២ៈ ០៥នាទី ។ ពេលនោះយើងបានជួបជាមួយប្រធានឃុំជលសារឈ្មោះ **ជង់ អ៊ុត** ។ លោកអ៊ំមានអាយុ៥៨ឆ្នាំ មានស្រុកកំណើតនៅភូមិទន្លេក្រៅ ឃុំជលសារ ។ បច្ចុប្បន្នរស់នៅភូមិឫស្សីនាងគួច ឃុំជលសារ ។ លោកអ៊ំបានប្រាប់ថា កាលពីឆ្នាំ១៩៧៨ មានមន្ទីរសន្តិសុខ

មួយកន្លែងស្ថិតនៅភូមិកំពង់បាស្រូវ ។ កាលនោះភូមិកំពង់បាស្រូវស្ថិតនៅក្នុងឃុំព្រៃគ្រី ។ ប្រជាជនដែលពួកខ្មែរក្រហមចាប់យកទៅដាក់នៅកន្លែងនោះ ព្រោះពួកខ្មែរក្រហមចោទថាជា **ខ្មែរស** ។ រួចក៏ពួកខ្មែរក្រហមស្រាវជ្រាវបន្តទៀត ជាពិសេសនៅក្នុងភូមិព្រែកគ្រប់ ខ្មែរក្រហមស្រាវជ្រាវឃើញមានប្រហែល៧០នាក់ជាខ្មែរស ។ ពេលចាប់គឺ មានចងស្លាបសេក រួចវាយសួរចម្លើយ ។ ពេលវាយនោះ ខ្មែរក្រហមសួររកបក្ខពួកជាខ្មែរសជាមួយ ។ ដំបូងគ្មាននរណាឆ្លើយទេ ប៉ុន្តែដល់មានបែកក្បាលហូរឈាម, វង្វេងស្មារតី ក៏នឹកឃើញចេះតែឆ្លើយផ្តេសផ្តាស់ដាក់គេដាក់ឯង ។ ក្រោយពីសួរចម្លើយរួច ក៏ត្រូវយកទៅវាយចោលនៅចំនុចព្រំប្រទល់ភូមិព្រែកគ្រប់ និង ភូមិកំពង់បាស្រូវ ។ លោកអ៊ឹំបានធ្វើការប៉ាន់ស្មានថា មានសាកសពប្រហែលជាង១០០នាក់ ។ ចំពោះរណ្តៅសាកសពវិញ លោកអ៊ឹំមិនបានដឹងទេ ។

អ្វីដែលលោកអ៊ឹំប្រធានឃុំបានរៀបរាប់ខាងលើ ជាព្រឹត្តិការណ៍ដែលបានកើតឡើងនៅឆ្នាំ១៩៧៤ ។ ចំណែកចាប់ពីឆ្នាំ១៩៧៥រហូតមកដល់ឆ្នាំ១៩៧៩ នៅឃុំជលសារ ជាពិសេសនៅភូមិកំពង់បាស្រូវអត់មានការសម្លាប់មនុស្សទេ ព្រោះអ្នកដែលមានទោសត្រូវបានពួកខ្មែរក្រហមបញ្ជូនមកកាន់ស្រុកកំពង់លែង ក្នុងឃុំប្រណ្តូក អស់គ្មានទុកនៅក្នុងឃុំជលសារទេ ។ លោកអ៊ឹំបានរៀបរាប់បន្តថា ប្រជាជនដែលត្រូវចាប់ខ្លួនដំបូងគឺពួកខ្មែរក្រហមបញ្ជូនទៅកាន់ភូមិចាស់ នៅមន្ទីរសន្តិសុខភូមិចាស់ បន្ទាប់មកបញ្ជូនទៅប្រណ្តូកតែម្តង ។

លោកមេឃុំបានប្រាប់បន្ថែមថា ចំពោះប្រជាជនដែលបានជន្លៀសមកពីភ្នំពេញទាំងទូកៗ ត្រូវបានពួកខ្មែរក្រហមយកមកសម្លាប់នៅ **ភូមិកោះគ្របបាយ** ស្ថិតនៅខាងជើងកំពង់ចម្លងកំពង់ហៅប្រហែល១គីឡូម៉ែត្រ ។ ភូមិកោះគ្របបាយ និង ភូមិតាអូរលំ ជាទីតាំងសម្លាប់មនុស្សធំប្រចាំឃុំកំពង់ហៅ ស្រុកកំពង់លែង ។ មូលហេតុ ដែលលោកមេឃុំរូបនោះដឹង ព្រោះនៅពេលដែលគាត់បានធ្វើដំណើរតាមទូក (ពេលទឹកតំឡើង) ទៅរុះរើផ្ទះមកធ្វើជាសហករណ៍ជាមួយមេកងឈ្មោះមិត្ត **ឡេង** នៅឆ្នាំ១៩៧៥ ។ លោកអ៊ឹំប្រធានឃុំជលសារបានប្រាប់ថា មានមនុស្សស្លាប់រាប់ពាន់នាក់ ហើយសុទ្ធតែជាប្រជាជនជន្លៀសពីភ្នំពេញទាំងអស់ ។

ក្រុមស្រាវជ្រាវយើងមិនបានធ្វើដំណើរទៅពិនិត្យដល់ទីតាំងនោះទេ ព្រោះពេលនេះជារដូវទឹកកំពុងតំឡើង ទីតាំងនោះត្រូវបានលិចទឹកអស់ហើយ ។ ម្យ៉ាងទៀតយើងពិបាកនឹងធ្វើដំណើរទៅកាន់ទីនោះផង ។

<u>សន្និដ្ឋាន</u>

នៅស្រុកជលគិរីនេះ យោងតាមការស្រាវជ្រាវរបស់ក្រុមយើងគឺតាំងពីឆ្នាំ១៩៧៥-៧៩ ពុំមានការសម្លាប់មនុស្សទេ ហើយក៏ពុំមានមន្ទីរសន្តិសុខដែរ ។ តាមសំដីរបស់មេឃុំមួយចំនួននៅស្រុកជលគិរី ជាពិសេស

ឃុំជលសារ, ឃុំព្រៃត្រី ថាមានការសម្លាប់មនុស្សខ្លះ ជាពិសេសទាហានលន់ណុល ប៉ុន្តែមិនមែននៅឆ្នាំ១៩៧៥ ទេ គឺសម្លាប់នៅឆ្នាំ១៩៧៤ ។ ចំណែកឯក្រោយឆ្នាំ១៩៧៥រហូតមកដល់ឆ្នាំ១៩៧៩ អ្នកទោសដែលត្រូវសម្លាប់គឺបញ្ជូនមកកាន់ស្រុកកំពង់លែងទាំងអស់ មិនមានការសម្លាប់នៅទីនោះទេ ។

ដោយយោលទៅលើអាកាសធាតុមិនល្អ ក្រុមយើងមិនបានចុះទៅដល់ទីតាំងមួយចំនួននៅស្រុកជលគិរីទេ ព្រោះក្រុមយើងយល់ថាជាការសម្លាប់មុនឆ្នាំ១៩៧៥ ។

<u>មនុស្សដែលគួរជួបនាពេលក្រោយ</u>

ដោយយើងមិនអាចចាំនៅជួបបាន ក្រុមយើងបានធ្វើដំណើរចាកចេញពីស្រុកកំពង់លែងឆ្ពោះទៅកាន់ស្រុកជលគិរីដែលជាទីតាំងចុងក្រោយរបស់ក្រុមយើងក្នុងដំណើរទៅកាន់ខេត្តកំពង់ឆ្នាំងលើកនេះ (ខែមិថុនា ឆ្នាំ២០០០) ។ ជនដែលក្រុមយើងចង់ជួបនោះឈ្មោះ **ខេ ខឿន** ដែលពីអតីតជំនាន់ខ្មែរក្រហម **ខឿន** ជាប្រធានសន្តិសុខភូមិចាស់ ឃុំដារ ។ ទោះបីជាពេលនោះ **ខឿន** មិនបានសម្លាប់មនុស្សដោយផ្ទាល់ដៃ ដូចដែលលោកពូប្រធានឃុំដារបានប្រាប់ក៏ដោយ ប៉ុន្តែយ៉ាងហោចណាស់ក៏ **ខឿន** បានចូលរួមក្នុងការសម្លាប់ជនស្លូតត្រង់តាមរយៈការបញ្ជារឲ្យកូនចៅយកមនុស្សទៅវៃចោលដែរ ។ ពេលយើងស្វែងរកជួបគាត់ពីរ-បីដងនាពេលនោះ (១២ ខែ មិថុនា ឆ្នាំ២០០០) គាត់មិនបាននៅផ្ទះឡើយ ។ លោកពូប្រធានឃុំដារ ជឹម ចុន បានប្រាប់ថា ខេ ខឿន មិនត្រូវបានធ្វើទារុណកម្មពីបណ្តាប្រជាជនក្នុងស្រុក-ភូមិទេ បើតាមសំដីរបស់ ជឹម ចុនថាប្រជាជនទាំងនោះគ្មានចិត្តចងអាឃាតទេ ។

តើពេលនោះ ខេ ខឿន បានធ្វើអ្វីខ្លះចំពោះប្រជាជន បានជាប្រជាជនទាំងនោះនៅតែទទួលស្វាគមន៍ឲ្យ ខេ ខឿន បន្តរស់នៅក្នុងស្រុកនេះតទៅទៀត? ឬមួយពិតជាមិនបានសម្លាប់មនុស្សមែន? ចុះហេតុអ្វីបានជា ខេ ខឿន ក្លាយជាប្រធានសន្តិសុខនាពេលនោះ (១៩៧៥)? ។

<u>**ទីតាំងដែលត្រូវចុះនាពេលក្រោយ**</u>

ក្រុមស្រាវជ្រាវយើងបានទទួលពត៌មានពីលោកមេឃុំជលសារមកថា មានកន្លែងសម្លាប់មួយកន្លែងទៀតដែលលាតសន្ធឹងពីភូមិកោះគ្របបាយដល់ភូមិតាអួរលំ ក្នុងឃុំកំពង់ហៅ ស្រុកកំពង់លែង ។ លោកមេឃុំរូបនោះបានប្រាប់ថា នៅទីនោះមានប្រជាជនជន្លៀសរាប់ពាន់នាក់ស្លាប់ ។ កន្លែងសម្លាប់ស្ថិតនៅតាមមាត់ទន្លេ ។ ប្រជាជនដែលបានមកស្លាប់នៅកន្លែងនេះច្រើនតែប្រជាជនជន្លៀសចេញពីទីក្រុងភ្នំពេញកាលពីឆ្នាំ១៩៧៥ ។

ក្រុមយើងមិនអាចធ្វើដំណើរបកក្រោយមករកទីតាំងនេះបានទេ ព្រោះនៅកន្លែងនោះ បច្ចុប្បន្នទឹកលិចអស់ហើយ មិនអាចឲ្យក្រុមយើងប្រើប្រាស់ម៉ាស៊ីនអក្ស ដើម្បីចុចយកទីតាំងទាំងនោះបានឡើយ និងម្យ៉ាងពេលវេលាខ្លី មិនអាចឲ្យយើងស្វែរករកអ្នកដឹងឮបាន ។

---